ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៦២/១១-ខេមបូ ហ៊ែនសាំ (សាខាទី១)

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ ក្រុមហ៊ុន **ខេមបូ ហ៊ែនសាំ អិលធីឌី (សាខាទី១)**

អាសយដ្ឋាន ៖ ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ២៤៩ ៦៣៣ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក Do Sang Kyu | Assistant CSR Manager |
| ២- លោក Soo Hyung Jo | CSR Manager |
| ៣- លោក ហំ ភា | មេធាវី |
| ៤- លោក ចាន់ ដារុធ | ប្រធានផ្នែករដ្ឋបាល |
| ៥- លោក ប៉ុន បូរិត | បុគ្គលិកផ្នែកច្បាប់ |
| ៦- លោក សួង ពិសិដ្ឋ | បុគ្គលិកផ្នែកច្បាប់ |
| ៧- លោក ហួត សុខ | បុគ្គលិកផ្នែកច្បាប់ |

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh◆ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org◆ Website: www.arbitrationcouncil.org

២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- **សហព័ន្ធសហជីពមិត្តភាពកម្មករ**

- **សហព័ន្ធសហជីពពលកម្មកម្ពុជា**
- **សហជីពពលកម្មកម្ពុជាក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី, ១**
- **សហជីពមិត្តភាពកម្មករក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី, ១**

អាសយដ្ឋាន ៖ ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៨ ៨៩ ៩៩ ៥៥៩, ០៧៧ ៥៥០ ៩៧៥ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក សុខ គ្រុយ | មេធាវី |
| ២- លោក សៀង សម្បត្តិ | ប្រធានសហព័ន្ធសហជីពមិត្តភាពកម្មករ |
| ៣- លោក ឌិន សំអាត | ប្រធានសហព័ន្ធសហជីពពលកម្មកម្ពុជា |
| ៤- លោក វ៉ាន់ វីន | ប្រធានសហជីពមិត្តភាពកម្មករប្រចាំក្រុមហ៊ុន |
| ៥- លោក យី ដាវី | អនុប្រធានសហជីពមិត្តភាពកម្មករប្រចាំក្រុមហ៊ុន |
| ៦- កញ្ញា ទីន ចាន់ណោក់ | លេខាធិការសហជីពមិត្តភាពកម្មករប្រចាំក្រុមហ៊ុន |
| ៧- លោក យី ដារុធ | ប្រធានសហជីពពលកម្មកម្ពុជាប្រចាំក្រុមហ៊ុន |
| ៨- លោក ស្រៀង ណារិទ្ធិ | អនុប្រធានសហព័ន្ធសហជីព CWEF |
| ៩- លោក អ៊ុន ដារ៉ា | ប្រធានសហព័ន្ធសហជីពស្មារតីកម្មករឯករាជ្យ |
| ១០- លោក យ៉ាំ ថៃសាន | អគ្គលេខាធិការសហភាពពលកម្មកម្ពុជា |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកលោក វ៉ាន់ វីន, លោក យី ដាវី ប្រធាន និងអនុប្រធានសហជីពមិត្តភាពកម្មករ និងលោក យី ដារុធ ប្រធានសហជីពពលកម្មកម្ពុជាចូលធ្វើការវិញ ។

២- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនដកពាក្យបណ្តឹងចោទប្រកាន់លោក វ៉ាន់ វីន ពីសាលាដំបូងរាជធានីភ្នំពេញ ។

៣- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្លាស់ប្តូរសន្តិសុខថ្មីប្រចាំក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ។

៤- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ថវិការថ្លៃឡានឬថវិការស្នាក់នៅចំនួន១៥ដុល្លាអាមេរិក ។

៥- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗ ជូនកម្មករនិយោជិតដែលបានចូលរួមធ្វើកូដកម្ម ។

៦- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនដករដ្ឋបាលក្រុមហ៊ុនចេញពីការងារ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីអំពីការមិនសះជាលេខ ១៣៤៨ កប/អក/វក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧
(ទល់មុខវិទ្យាល័យតន្ត្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ (វេលាម៉ោង ២ រសៀល ) ។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ កម្មករនិយោជិតជាង៤០០នាក់ ដឹកនាំដោយសហព័ន្ធសហជីពមិត្តភាពកម្មករបានធ្វើកូដកម្ម ដើម្បីទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ និងទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពឈ្មោះ វ៉ាន់ វីន និង ឈ្មោះ យី ដាវី ជាប្រធាន និងអនុប្រធានសហជីពមិត្តភាពកម្មករ និងថ្នាក់ដឹកនាំសហជីពឈ្មោះ យី ដាវុធ អនុប្រធានសហជីពពលកម្មកម្ពុជាប្រចាំក្រុមហ៊ុនចូលធ្វើការវិញ។ បន្ទាប់ពីបានទទួលបណ្ដឹងនេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញចុះធ្វើការដោះស្រាយវិវាទការងាររួមនេះ ដល់ទីតាំងក្រុមហ៊ុនផ្ទាល់ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នា លើការទាមទារសរុបចំនួន ០៦ ចំណុចនេះទេ។ ចំណុចមិនសះជាចំនួន ០៦ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១៣៤៨ កប/អក/វក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៦ ចំណុចនេះ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង២រសៀល។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និង

បានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០៦ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន០៣ ចំណុច គឺចំណុចវិវាទទី៣ ទី៤ និងទី៦។ ចំណុចមិនសះជា ដែលនៅសល់ គឺចំណុចវិវាទទី១ ចំណុចវិវាទទី២ និង ចំណុចវិវាទទី៥។

នៅក្នុងសំណុំរឿងនេះ ភាគីវិវាទទាំងពីរជ្រើសរើសយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ច។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង ÷**

សាក្សី ៖ លោក ម៉ុម សំរេច កស្សិណសាក្សីក្នុងនាមនិយោជក

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់នាយកក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ជូនលោកមេធាវី ហំ ភា ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ។

២- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ជូនលោក Do Sang Kyu ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ។

៣- ថាសវីដេអូចំនួន ០១ បន្ទះ ទាក់ទងនឹងសកម្មភាពនៅថ្ងៃធ្វើកូដកម្មនៅក្រុមហ៊ុម ខេមបូ ហ៊ែនសាំ។

៤- អង្គហេតុទាក់ទងនឹងការចោទប្រកាន់លោក វ៉ាន់ រីន លួចអាវរបស់ក្រុមហ៊ុន និងការចោទប្រកាន់កម្មករ យី ដារ៉ុធ និង យី ដាវី ដើរស្រែករំខានដល់កម្មករដទៃ ។

៥- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ ។

៦- លក្ខន្តិកៈក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ ។

៧- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ។

៨- កំណត់ហេតុរបាយការណ៍ប្រជុំ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ទាក់ទងនឹងបញ្ហាលួចអាវរបស់លោក វ៉ាន់ រីន ។

៩- របាយការណ៍សន្តិសុខឈ្មោះ ម៉ុម សំរេច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ទាក់ទងនឹងបញ្ហាលួចអាវរបស់លោក វ៉ាន់ រីន ។

១០- របាយការណ៍របស់ឈ្មោះ អ៊ុង អាន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ពីការមិនចូលធ្វើការរបស់លោក វ៉ាន់ រីន ។

១១- កំណត់ហេតុរបស់ឈ្មោះ ហោ សង្ហា ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ថា បានឃើញឈ្មោះ វ៉ាន់

វីន ទៅកន្លែងចតម៉ូតូនាវេលាម៉ោង ១១ និង ១៥ នាទី។

១២- កំណត់ហេតុកម្មកររបស់ឈ្មោះ សួន សុភាព ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ថា បានឃើញឈ្មោះ វ៉ាន់ វីន ចេញមុនម៉ោង ទៅកន្លែងចតម៉ូតូនាវេលាម៉ោង ១១ និង ១៨ នាទី។

១៣- កំណត់ហេតុរបស់ឈ្មោះ ស្រី ច្រិប ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ពីឈ្មោះ យី ដាវី និង យី ដាវុធ បានដើរស្រែកមិនឱ្យកម្មករធ្វើការ និងស្រែកជេរប្រមាថដល់ប្រធានក្រុមនាវេលាម៉ោង ១២ និង ៤៥ នាទី នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

១៤- កំណត់ហេតុរបស់ឈ្មោះ ស៊ឹម ខ្លី ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ពីឈ្មោះ យី ដាវី និង យី ដាវុធ បានដើរស្រែកមិនឱ្យកម្មករធ្វើការ នាវេលាម៉ោង ១២ និង ៤០ នាទី នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

១៥- កំណត់ហេតុរបស់ឈ្មោះ ឈិន សុខន ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ពីឈ្មោះ យី ដាវី និង យី ដាវុធ បានដើរស្រែកក្នុងកន្លែងការងារមិនឱ្យកម្មករធ្វើការ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។

១៦- កំណត់ហេតុរបស់ឈ្មោះ ចំរើន សាវ៉ន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ពីឈ្មោះ យី ដាវី និង យី ដាវុធ បានដើរស្រែកមិនឱ្យកម្មករធ្វើការ នាវេលាម៉ោង ១២ និង ៣០ នាទី នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

១៧- កំណត់ហេតុរបស់ឈ្មោះ ស៊ឹម ចាន់ណា ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ពីឈ្មោះ យី ដាវី និង យី ដាវុធ បានដើរស្រែកមិនឱ្យកម្មករធ្វើការ នាវេលាម៉ោង ១២ និង ៤០ នាទី នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

១៨- ការឃើញកម្មករជាច្រើនមិនបានធ្វើការរហូតដល់ម៉ោង ៤ ល្ងាច របស់ឈ្មោះ ហុង សាមរី ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១១ ។

១៩- ការឃើញឈ្មោះ យី ដាវី និង យី ដាវុធ គាត់បានដើរស្រែកឱ្យកម្មករកម្មការិនីទាំងអស់មិនឱ្យធ្វើការ របស់ឈ្មោះ អយ ចាន់ធូ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១១ ។

២០- កំណត់ហេតុរបស់ឈ្មោះ ទុំ សាវិន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ពីឈ្មោះ យី ដាវី និង យី ដាវុធ បានដើរស្រែកតាមក្រុមដេរ មិនឱ្យកម្មករធ្វើការ នាវេលាម៉ោង ១២ និង ៤០ នាទី នៅថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ២០១១។

២១- កំណត់ហេតុរបស់កម្មករឈ្មោះ សំ ផល ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ពីឈ្មោះ យី ដាវី និង យី ដាវុធ បានដើរស្រែកតាមក្រុមដេរ មិនឱ្យកម្មករធ្វើការ នាវេលាម៉ោង ១២ និង ២០ នាទី ដល់ម៉ោង ៤ល្ងាច នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១១។

២២- កំណត់ហេតុរបស់ឈ្មោះ សែន ចាន់ទី ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ពីឈ្មោះ យី ដាវី និង យី ដាវុធ បានដើរស្រែកតាមក្រុមដេរ និងបង្កភាពចលាចលនៅក្នុងរោងចក្រ នាពេលរសៀល នៅថ្ងៃទី

២៥ ខែ វិច្ឆិកា ឆ្នាំ២០១១។

២៣- កំណត់ហេតុរបស់ឈ្មោះ សាម ស៊ីយ៉ន ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ពីឈ្មោះ យី ដាវី និង យី ដាវុធ បានដើរស្រែកតាមក្រុមដេរ មិនឱ្យកម្មករធ្វើការ នាវេលាម៉ោង ១២ និង ៤០ នាទី ដល់ម៉ោង ៤ល្ងាច នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១១។

២៤- កំណត់ហេតុរបស់ឈ្មោះ កង សុខមាន ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ បញ្ជាក់ពីឈ្មោះ យី ដាវី និង យី ដាវុធ បានដើរស្រែកតាមក្រុមដេរ មិនឱ្យកម្មករធ្វើការ នាវេលាម៉ោង ១២ និង ៤០ នាទី នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១១។

២៥- របាយការណ៍របស់ឈ្មោះ ប៊ុន បូរិត ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ បញ្ជាក់ពីសកម្មភាពក្នុងរោងចក្រ នៅថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ទាក់ទងនឹងបញ្ហាការលួចអាវរបស់លោក វ៉ាន់ រីន។

២៦- របាយការណ៍របស់សន្តិសុខសុវត្ថិភាពឈ្មោះ ដៀប សីហា ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ បញ្ជាក់ពីឈ្មោះ យី ដាវី និង យី ដាវុធ បានដើរស្រែកតាមក្រុមដេរ មិនឱ្យកម្មករធ្វើការ នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១១។

២៧- តារាងប្រាក់បៀវត្សប្រចាំខែ ១១ ឆ្នាំ២០១១ Line ១២ (B), Line ១៤ (B), Line ១៣ (B) , Line ១៥ (B), Line ១៦ (B), Line ១៧ (B) , Line ២០ (B), Line ២១ (B), Line ២២ (B), Line ២៤ (B) ។

២៨- របាយការណ៍សំភាសន៍កម្មករឈ្មោះ ញ៉ គៀត, ទៀង ផន, ជឿន សុខា, ម៉េត ភក្តី, ឈិន សុខុម, យ៉ន់ វុធ , ម៉េង ស្រីនាង , វ័ន សាម៉េន, ហៀន គឹមហៀង , នៅ ចិន្តា ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ទាក់ទងនឹងបុគ្គលិកលក្ខណៈរបស់លោក ចាន់ ដាវុធ ។

២៩- កំណត់ហេតុអនុវត្ត ដីកាសម្រេចរក្សាការពារលេខ ១៦ “ជ” ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១ ។

៣០- ដីការសំរេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ លេខ ១៦ "ជ" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០១១ ។

៣១- លិខិតរបស់នាយក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការជូនដំណឹងស្តីពីការព្យួរការងាររបស់ឈ្មោះ វ៉ាន់ រីន ផ្នែកអ៊ុត ជាប្រធានសហជីពមិត្តភាពកម្មករ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៣២- លិខិតរបស់នាយក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការជូនដំណឹងស្តីពីការព្យួរការងាររបស់ឈ្មោះ យី ដាវី ផ្នែកជាងម៉ាស៊ីន ជាអនុប្រធានសហជីពមិត្តភាពកម្មករ និង យី ដាវុធ ផ្នែកជាងម៉ាស៊ីន ជាប្រធានសហជីពពលកម្មកម្ពុជាប្រចាំរោងចក្រ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។

6

៣៣- លិខិតរបស់នាយក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការស្នើសុំបញ្ឈប់ការងារលោក វ៉ាន់ រីន អត្តលេខ ៥-១០៦៥ ជាកម្មករផ្នែកអ៊ុត និងជាប្រធានសហជីពមិត្តភាពកម្មករ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។

៣៤- លិខិតរបស់នាយក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការស្នើសុំបញ្ឈប់ឈ្មោះ យី ដាវី អត្តលេខ ៨៨៥៨ ជាធ្វើការនៅផ្នែកជាងម៉ាស៊ីន និងជាអនុប្រធានសហជីពមិត្តភាពកម្មករ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។

៣៥- លិខិតរបស់នាយក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការស្នើសុំបញ្ឈប់ឈ្មោះ យី ដារុំធ អត្តលេខ ៦២១១ ជាធ្វើការនៅផ្នែកជាងម៉ាស៊ីន និងជាប្រធានសហជីពពលកម្មកម្ពុជា ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់លោក យី ដារុំធ, យី ដាវី និង វ៉ាន់ រីន ជូនលោកមេធាវី សុខ គ្រុយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ ។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពពលកម្មកម្ពុជាក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ១ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ។

៣- លិខិតរបស់នាយកដ្ឋានវិវាទការងារលេខ ៦៤៣ កប/អក/វក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ជម្រាបមកលោកប្រធានសហជីពមិត្តភាពកម្មករក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ស្តីពីការសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី ។

៤- លិខិតបញ្ជាក់ពីភាពពេញលក្ខណៈច្បាប់របស់សហជីពមិត្តភាពកម្មករក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ លេខ ១៨០ កប ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០ ។

៥- សេចក្តីថ្លែងការណ៍រួមរបស់សហភាពជាតិកម្ពុជាការពារកម្មករមាន ៨ សហព័ន្ធ,សម្ព័ន្ធសហព័ន្ធសហជីពជាតិកម្ពុជាមាន៦សហព័ន្ធ, សហភាពពលកម្មជាតិកម្ពុជាមាន ៥ សហព័ន្ធ និងសហព័ន្ធសហជីពឯករាជ្យចំនួន ៦ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៦- លិខិតរបស់សហភាពជាតិកម្ពុជាការពារកម្មករមាន ៨ សហព័ន្ធ,សម្ព័ន្ធសហព័ន្ធសហជីពជាតិកម្ពុជាមាន ៦ សហព័ន្ធ, សហភាពពលកម្មជាតិកម្ពុជាមាន ៥ សហព័ន្ធ និងសហព័ន្ធសហជីពឯករាជ្យមាន ៦ សហព័ន្ធ គោរពចូលមកលោកអធិការនគរបាលរដ្ឋបាលខណ្ឌដង្កោ ស្តីពីការស្នើសុំដោះលែងលោក វ៉ាន់ រីន ដែលជាប្រធានសហជីពមិត្តភាពកម្មករប្រចាំរោងចក្រ ខេមបូ ហ៊ែនសាំ ១ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៧- លិខិតស្នើរសុំអន្តរាគមន៍របស់កម្មករ កម្មការិនីនៃរោងចក្រ ខេមបូ ហ៊ែនសាំ ១ សូមគោរពជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការស្នើសុំជួយ

អន្តរាគមន៍ចំពោះរោងចក្រ ខេមបូ ហ៊ែនសាំ ១ ឱ្យដកពាក្យបណ្តឹងដែលក្រុមហ៊ុនបានប្រើល្បិចប្តឹងថ្នាក់នាំសហជីពទៅតុលាការ និងព្យួរកិច្ចសន្យាថ្នាក់ដឹកនាំសហជីពចំនួន ០៣ រូប ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៨- លិខិតពឹងពាក់របស់កម្មករកម្មការិនីនៃរោងចក្រ ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកស្រីប្រធានសម្ព័ន្ធសហព័ន្ធសហជីពជាតិកម្ពុជា, លោកប្រធានសហភាពជាតិកម្ពុជាការពារកម្មករ, លោកប្រធានសហព័ន្ធសហជីពកម្មករខ្មែរ,លោកប្រធានសហព័ន្ធសហជីពចលនាកម្មករ និងលោកប្រធានសហព័ន្ធសហជីពការពារកម្មករ ស្តីពីការស្នើសុំជួយអន្តរាគមន៍រកដំណោះស្រាយជាមួយនាយករោងចក្រ ខេមបូ ហ៊ែនសាំ ១ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ ។

៩- លិខិតរបស់នាយក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការជូនដំណឹងពីការព្យួរការងាររបស់ឈ្មោះ វ៉ាន់ រីន ផ្នែកអ៊ុត ជាប្រធានសហជីពមិត្តភាពកម្មករ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។

១០- លិខិតរបស់នាយក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការជូនដំណឹងពីការព្យួរការងាររបស់ឈ្មោះ យី ដាវី ផ្នែកជាងម៉ាស៊ីន ជាអនុប្រធានសហជីពមិត្តភាពកម្មករ និង យី ដាវុធ ផ្នែកជាងម៉ាស៊ីន ជាប្រធានសហជីពពលកម្មកម្ពុជាប្រចាំរោងចក្រ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។

១១- លិខិតបញ្ជាក់របស់ឈ្មោះ វ៉ាន់ រីន បញ្ជាក់ពីការមិនបានលួចអាវរបស់ខ្លួនដោយមានសាក្សីចំនួន២៣នាក់ផ្តិតមេដៃអម ។

១២- សារណាការពាររបស់សហព័ន្ធសហជីពពលកម្មកម្ពុជា ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ។

១៣- លក្ខន្តិកៈសហជីពពលកម្មកម្ពុជាក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ។

១៤- បញ្ជីរាយនាមកម្មករកម្មការិនីចូលរួមគាំទ្រធ្វើកូដកម្ម ដើម្បីទាមទារលក្ខខណ្ឌការងារក្នុងរោងចក្រ ខេមបូ ហ៊ែនសាំ ១ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១១ ។

១៥- លិខិតរបស់សហព័ន្ធសហជីពមិត្តភាពកម្មករលេខ ០៦១/១១ សមក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១១ គោរពជូនលោកនាយកក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ស្តីពីការស្នើសុំជួយដោះស្រាយលក្ខខណ្ឌការងារ ។

១៦- ពាក្យបណ្តឹងរបស់កម្មករកម្មការិនីបំរើការងារក្នុងរោងចក្រ ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកប្រធានសហព័ន្ធសហជីពមិត្តភាពកម្មករ ស្តីពីការស្នើសុំជួយដោះស្រាយលក្ខខណ្ឌការងារ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១១ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ១ លេខ

១៣៤៨ កប/អក/វក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ១ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៨៨៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៨៨៧ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី១ មានជួលកម្មករនិយោជិតសរុបចំនួន ២០០០ នាក់។
- សហជីពមិត្តភាពកម្មករ និងសហជីពពលកម្មកម្ពុជា ជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។

ចំណុចវិវាទទី១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកលោក វ៉ាន់ វីន លោក យី ដាវី ប្រធាន និងអនុប្រធានសហជីពមិត្តភាពកម្មករ និងលោក យី ដារ៉ុធ ប្រធានសហជីពពលកម្មកម្ពុជាចូលធ្វើការវិញ

- ភាគីនិយោជកបានចោទប្រកាន់លោក វ៉ាន់ វីន ប្រធានសហជីពមិត្តភាពកម្មករ ថា បានលួចអាវរបស់ក្រុមហ៊ុនដាក់ក្នុងកែបម៉ូតូរបស់គាត់ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។ និយោជកបានសម្រេចព្យួរកិច្ចសន្យាការងាររបស់កម្មកររូបនេះនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ តែម្តង។
- ភាគីនិយោជកបានចោទប្រកាន់លោក យី ដាវី អនុប្រធានសហជីពមិត្តភាពកម្មករ និងលោក យី ដារ៉ុធ ប្រធានសហជីពពលកម្មកម្ពុជា ថា បានដើររំខានដល់កម្មករក្នុងម៉ោងធ្វើការ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។ និយោជកក៏បានសម្រេចព្យួរកិច្ចសន្យាការងាររបស់កម្មករទាំងពីររូបនេះ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ដែរ។
- ភាគីនិយោជកបានស្នើសុំបញ្ឈប់កម្មករនិយោជិតទាំងបីរូបនេះ ទៅនាយកដ្ឋានវិវាទការងារ តាមរយៈលិខិតស្នើសុំ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។
- កម្មករ វ៉ាន់ វីន បានជំទាស់ថា គាត់មិនបានលួចអាវរបស់ក្រុមហ៊ុនដូចការចោទប្រកាន់ទេ។ ចំណែកកម្មករ យី ដាវី និង យី ដារ៉ុធ ក៏បានជំទាស់ផងដែរថា ពួកគាត់ក៏មិនបានដើររំខានដល់កម្មករក្នុងម៉ោងធ្វើ

ការដូចការចោទប្រកាន់របស់ភាគីនិយោជកដែរ។

- ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបញ្ឈប់ការព្យួរការងារ និងទទួលយកពួកគាត់ចូលធ្វើការធម្មតាវិញ។
- រហូតមកដល់ថ្ងៃចេញសេចក្តីបង្គាប់នេះ អធិការការងារមិនទាន់បានចេញសេចក្តីសម្រេចណាមួយនៅឡើយ ទាក់ទងទៅនឹងបណ្តឹងនេះ ហើយវាក៏មិនទាន់ផុតរយៈពេលកំណត់មួយខែ ដែលអធិការការងារត្រូវចេញនូវសេចក្តីសម្រេចដែរ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនដកពាក្យបណ្តឹងចោទប្រកាន់លោក វ៉ាន់ វីន ពីសាលាដំបូងរាជធានីភ្នំពេញ**

- ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកដកពាក្យបណ្តឹងចោទប្រកាន់លោក វ៉ាន់ វីន ពីសាលាដំបូងរាជធានីភ្នំពេញ។
- ភាគីនិយោជកមិនឯកភាពនឹងការទាមទារនេះទេ។

**ចំណុចវិវាទទី ៥ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗជូនកម្មករនិយោជិត ដែលបានចូលរួមធ្វើកូដកម្ម**

- ភាគីកម្មករនិយោជិតបញ្ជាក់ថា ពួកគាត់នៅតែទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួលក្នុងអំឡុងពេលកូដកម្មប៉ុណ្ណោះ។ ចំណែកប្រាក់រង្វាន់ផ្សេងៗក្នុងអំឡុងពេលកូដកម្ម កម្មករនិយោជិតឈប់ធ្វើការទាមទារហើយ ពីព្រោះពួកគាត់បានទទួលប្រាក់រង្វាន់នេះរួចហើយ ពីនិយោជក។
- មានកូដកម្មកើតឡើងពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១។
- ភាគីកម្មករនិយោជិតលើកឡើងក្នុងសវនាការថា មានកម្មករនិយោជិតចំនួន ១០០០ នាក់ បានចូលរួមធ្វើកូដកម្ម។ ភាគីនិយោជកមិនបានជំទាស់នឹងការលើកឡើងនេះទេ។
- កម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលក្នុងអំឡុងពេលកូដកម្មនេះ ពីព្រោះពួកគាត់យល់ឃើញថា កូដកម្មកើតមានឡើងដោយសារនិយោជកជាអ្នករៀបចំគម្រោងធ្វើការចោទប្រកាន់ប្រធានសហជីពមិត្តភាពកម្មករ លោក វ៉ាន់ វីន ថា បានលួចអាវរបស់ក្រុមហ៊ុន។
- ភាគីនិយោជកមិនយល់ព្រមនឹងការទាមទារទេ ដោយបញ្ជាក់ថា តាមច្បាប់ស្តីពីការងារ ទោះបីជាកូដកម្មស្របច្បាប់ ឬមិនស្របច្បាប់ក៏ដោយ គឺកូដករមិនអាចទទួលបាននូវប្រាក់ឈ្នួលទេ។

## ហេតុផលនៃសេចក្តីសម្រេច ÷

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកលោក វ៉ាន់ វីន លោក យី ដាវី ប្រធាន និងអនុប្រធានសហជីពមិត្តភាពកម្មករ និងលោក យី ដាវុធ ប្រធានសហជីពពលកម្មកម្ពុជាចូលធ្វើការវិញ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើនិយោជកមានកាតព្វកិច្ចទទួលយកថ្នាក់ដឹកនាំសហជីពទាំងបី

6

របចូលធ្វើការវិញដែរ ឬទេ បន្ទាប់ពីនិយោជកស្នើសុំបញ្ឈប់ពួកគាត់ទៅអធិការការងារ ដោយមិនទាន់ទទួលបាន ការឆ្លើយតប និងមិនទាន់បានផុតរយៈពេលកំណត់ឆ្លើយតប?

មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារ កថាខណ្ឌទី១ និងទី២ បានចែងថា ៖

*"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់ បេក្ខជនណាមួយពីការងាររបស់ខ្លួនអាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ ។...*

*អធិការការងារដែលបានទទួលពាក្យបណ្តឹងសុំបញ្ឈប់កម្មករនិយោជិតដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនដល់និយោជក ដល់កម្មករនិយោជិតដែលត្រូវបញ្ឈប់ ....ក្នុងរយៈពេលមួយខែយ៉ាងយូរក្រោយ ទទួលពាក្យបណ្តឹង ។*

*បន្ទាប់ពីបានទទួលសេចក្តីសម្រេចនោះ និយោជក កម្មករនិយោជិត ដែលត្រូវបញ្ឈប់ ឬអង្គការសហជីពរបស់កម្មករនិយោជិតនោះ មានរយៈពេលពីរខែ ដើម្បីធ្វើឧបាស្រ័យ ទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារអាចបដិសេធចោល ឬកែសម្រួលសេចក្តីសម្រេចរបស់អធិការការងារ"* ។

មាត្រានេះ ក៏ត្រូវបានអនុវត្តចំពោះថ្នាក់ដឹកនាំសហជីពផងដែរ ដូចមានចែងក្នុងប្រការ៤ នៃប្រកាសលេខ ៣០៥ សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលចែងថា *"... ការការពារនេះ ត្រូវបានផ្តល់ឱ្យថ្នាក់ដឹកនាំសហជីព០៣រូបក្នុងលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ២៨២ និង ២៩៣ នៃច្បាប់ស្តីពីការងារ ..."* ។

តាមមាត្រា២៩៣ នៃច្បាប់ស្តីពីការងារ អធិការការងារមានតួនាទីពិចារណាស្រាវជ្រាវ និងសម្រេចផ្តល់ការអនុញ្ញាត ឬបដិសេធចំពោះសំណើរបស់និយោជក ដែលសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីព។

ដោយហេតុថា នៅក្នុងសំណុំរឿងនេះ និយោជកបានដាក់ពាក្យបណ្តឹងស្តីពីការសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងបី គឺលោក វ៉ាន់ រីន លោក យី ដាវី និង លោក យី ដាវុធ ទៅនាយកដ្ឋានវិវាទការងារ តាំងពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០១១។ រហូតមកដល់ថ្ងៃចេញសេចក្តីបង្គាប់នេះ អធិការការងារមិនទាន់បានចេញសេចក្តីសម្រេចណាមួយនៅឡើយ ទាក់ទងទៅនឹងបណ្តឹងនេះ ហើយវាក៏មិនទាន់ផុតរយៈពេលកំណត់មួយខែ ដែលអធិការការងារត្រូវចេញនូវសេចក្តីសម្រេចដែរ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទនេះកំពុងស្ថិតនៅក្រោមសមត្ថកិច្ចរបស់អធិការការងារ ដែលត្រូវធ្វើសេចក្តីសម្រេចតាមការកំណត់នៃមាត្រា២៩៣ នៃច្បាប់ស្តីពីការងារ។ លើសពីនេះ ផ្អែកតាមមាត្រា២៩៣ ដដែល បន្ទាប់ពីបានទទួលសេចក្តីសម្រេចពីអធិការការងារហើយ និយោជក និងកម្មករនិយោជិតដែលពាក់ព័ន្ធក្នុងសំណុំរឿងនេះ មានរយៈពេលពីរខែ ដើម្បីធ្វើឧបាស្រ័យ ទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារអាចបដិសេធចោល ឬកែសម្រួលសេចក្តីសម្រេចរបស់អធិការការងារ។

ក្នុងករណីនេះ ចំណុចវិវាទនេះនៅមិនទាន់បានបញ្ចប់ជាស្ថាពរនៅឡើយទេ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចពិចារណាលើការទាមទារនេះបានទេ។ (សូមមើលសេចក្តីបង្គាប់សេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ៧៥/០៦-វ៉ូ ស៊ូ ស៊ី អេន អេស ហេតុផលចំណុចវិវាទទី១ និងលេខ ១៦/១១-ខេមបូ ហ៊ើនសាំ ហេតុផលចំណុចវិវាទទី២*)។

ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទារឱ្យនិយោជកទទួលយកលោក វ៉ាន់ វីន លោក យី ដាវី និងលោក យី ដាវុធ ចូលធ្វើការធម្មតាវិញ ក្នុងខណៈពេលដែលសំណុំរឿងនេះកំពុងស្ថិតក្នុងសមត្ថកិច្ចរបស់អធិការការការងារនៅឡើយ ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកដកពាក្យបណ្តឹងចោទប្រកាន់លោក វ៉ាន់ វីន ពីសាលាដំបូង រាជធានីភ្នំពេញ**

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកដកពាក្យបណ្តឹងចោទប្រកាន់លោក វ៉ាន់ វីន ពីសាលាដំបូងរាជធានីភ្នំពេញ ។ ភាគីនិយោជកមិនឯកភាពនឹងការទាមទារនេះទេ ។

ដោយអនុលោមទៅតាមជំពូក១២ ផ្នែកទី២ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការក្នុងការសម្រេចតែលើវិវាទការងាររួមប៉ុណ្ណោះ ។ (សូមមើលសេចក្តីបង្គាប់សេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ៩៤/០៤-អេ អាយ អេ ហេតុផលចំណុចវិវាទទី៦, លេខ ៨១/០៦-ហុង អ៊ី ហេតុផលចំណុចវិវាទទី១ និងលេខ ៨៣/០៦-ហេតុផលចំណុចវិវាទទី១)* ។

មាត្រា៣០២ នៃច្បាប់ការងារចែងថា ៖ *"វិវាទការងាររួម គឺជាវិវាទដែលកើតឡើង... អំពីរឿងល័ក្ខខ័ណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈ ក្នុងសហគ្រាស ... រវាងនិយោជក និងកម្មករនិយោជិត..."* ។ តាមរយៈមាត្រានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មវត្ថុចម្បងនៃវិវាទការងាររួម ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការសម្រេចលើ គឺជាវិវាទការងាររួម ដែលទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាសជាដើម ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារនៅក្នុងចំណុចនេះ ដែលឱ្យនិយោជកដកពាក្យបណ្តឹងចោទប្រកាន់លោក វ៉ាន់ វីន ពីសាលាដំបូងរាជធានីភ្នំពេញ មិនមានកម្មវត្ថុដូចដែលមាត្រា៣០២ ខាងលើបានកំណត់ពីនិយមន័យនៃវិវាទការងាររួម ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការដោះស្រាយនោះទេ ។ ការទាមទារឱ្យនិយោជកដកពាក្យបណ្តឹងចំពោះកម្មករនិយោជិតណាម្នាក់នៅឯតុលាការអាជ្ញាធគតិ មិនស្ថិតក្នុងដែនយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកដកពាក្យបណ្តឹងចោទប្រកាន់លោក វ៉ាន់ វីន ពីសាលាដំបូងរាជធានីភ្នំពេញ ។

**ចំណុចវិវាទទី ៥ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួលជូនកម្មករនិយោជិត ដែលបានចូលរួមធ្វើកូដកម្ម**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតក្នុងអំឡុងពេលធ្វើកូដកម្មដែរ ឬទេ?

មាត្រា៣៣២ នៃច្បាប់ស្តីពីការងារចែងថា *"កិច្ចសន្យាការងារត្រូវព្យួរនៅពេលធ្វើកូដកម្ម ។ ក្នុងអំឡុងពេលនៃកូដកម្ម តាវកាលិកការងារមិនត្រូវបានផ្តល់ឱ្យទេ ហើយប្រាក់បៀវត្សមិនត្រូវបានបើកឱ្យដែរ"* ។

ទាក់ទងនឹងខ្លឹមសារនៃមាត្រានេះ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែបដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកផ្តល់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ក្នុងអំឡុងពេលកូដកម្ម ព្រោះច្បាប់ការងារបានបញ្ជាក់ថា កិច្ចសន្យាការងារត្រូវព្យួរនៅពេលធ្វើកូដកម្ម ហើយក្នុងអំឡុងពេលធ្វើកូដកម្ម តាវកាលិកការងារមិនត្រូវបានផ្តល់ឱ្យទេ ហើយប្រាក់បៀវត្សមិនត្រូវបានបើកឱ្យដែរ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ០៤/០៣-លីដា ហេតុផលនៃចំណុចវិវាទ១ និងលេខ ៦៣/០៧-ភ្នំពេញ ហ្គាមិន ហេតុផលចំណុចវិវាទទី១)*។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយរបស់អាជ្ញាកណ្តាលក្នុងសំណុំរឿងមុនដែរ។

ម្យ៉ាងវិញទៀត បើយោងតាមមាត្រា៣៣៤ នៃច្បាប់ស្តីពីការងារចែងថា “*ក្នុងអំឡុងពេលធ្វើកូដកម្ម ត្រូវហាមឃាត់មិនឱ្យនិយោជកជ្រើសរើសកម្មករនិយោជិតផ្សេងមកជំនួសកូដករទាំងអស់ លើកលែងតែការជ្រើសរើសនេះ ធ្វើឡើងដើម្បីធានាសេវាអប្បបរមាដូចមានចែងក្នុងមាត្រា៣២៦ និងមាត្រា៣២៨ ដែលកម្មករនិយោជិតជាប់កេណ្ឌក្នុងសេវានេះ មិនមកបង្ហាញខ្លួនដើម្បីធ្វើការ។ រាល់ការរំលោភវិធាននេះ តម្រូវឱ្យនិយោជកមានកាតព្វកិច្ចបើកប្រាក់បៀវត្សន៍ឱ្យកម្មករនិយោជិតជាកូដករទាំងអស់ នៅក្នុងរយៈពេលធ្វើកូដកម្ម* ”។ តាមរយៈមាត្រានេះ គឺក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសម្រេចឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត នៅពេលដែលកម្មករនិយោជិតបានបង្ហាញភស្តុតាងថា និយោជកបានធ្វើការជ្រើសរើសកម្មករនិយោជិតថ្មី មកជំនួសកម្មករនិយោជិតដែលធ្វើកូដកម្ម។ ក្នុងសំណុំរឿងនេះ មិនមានអង្គហេតុដែលនិយោជកជ្រើសរើសកម្មករថ្មី មកជំនួសកម្មករនិយោជិតដែលធ្វើកូដកម្មទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលក្នុងអំឡុងពេលធ្វើកូដកម្ម។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១៖** បដិសេធពិចារណាការទាមទារឱ្យនិយោជកទទួលយក លោក វ៉ាន់ វីន លោក យី ដាវី និង លោក យី ដារ៉ុច ចូលធ្វើការធម្មតាវិញ ក្នុងខណៈពេលដែលសំណុំរឿងនេះកំពុងស្ថិតក្នុងសមត្ថកិច្ចរបស់អធិការការការងារនៅឡើយ។

**ចំណុចវិវាទទី ២៖** បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជក ដកពាក្យបណ្តឹងចោទប្រកាន់ លោក វ៉ាន់ វីន ពីសាលាដំបូងរាជធានីភ្នំពេញ។

**ចំណុចវិវាទទី៥៖** បដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលក្នុងអំឡុងពេលធ្វើកូដកម្ម។

ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់ជាប់កាតព្វកិច្ច

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្ដង បន្ទាប់ពីសេចក្ដីបង្គាប់នេះចេញទៅ ដោយសារភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្ដីបង្គាប់ជាប់កាតព្វកិច្ច នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុង សុទ្ធី**

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា: ------------------------------------